# ការណែនាំអំពីការដំឡើង
# DRC-003



# I. សេចក្តីផ្តើម

ឧបករណ៍បញ្ជាផ្តាច់ភ្ជាប់ពីចម្ងាយ DRC-003 គឺជាឧបករណ៍បញ្ជាវៃឆ្លាត ដែលបំពាក់ជាមួយ Auto Reclosers Cooper ដើម្បីបញ្ជា និងត្រួតពិនិត្យទិន្នន័យពីចម្ងាយ ។ ឧបករណ៍បញ្ជាផ្តាច់ភ្ជាប់ពីចម្ងាយ DRC-003 ផ្តល់ភាពងាយស្រួល និងអនុញ្ញាតអោយក្រុមការងារបច្ចេកទេសអគ្គិសនីអាច គ្រប់គ្រង បញ្ជា និងត្រួតពិនិត្យបណ្តាញអគ្គិសនីតុងស្យុងមធ្យម ២២ គីឡូវ៉ុល និង ៣៥ គីឡូវ៉ុលប្រកបទៅដោយប្រសិទ្ធភាពខ្ពស់ ។ អត្ថប្រយោជន៍ដែលទទួលបានពីឧបករណ៍បញ្ជាផ្តាច់ភ្ជាប់ពីចម្ងាយ DRC-003 មានដូចជាៈ ជូនដំណឹងព័ត៌មានកំហូចនៅលើបណ្តាញ ទាញយកព័ត៌មានបន្ទុកប្រើប្រាស់ ព័ត៌មានថាមពល និងផ្តល់ព័ត៌មានសំខាន់ៗផ្សេងទៀត ដើម្បីជួយកាត់បន្ថយការដាច់ចរន្តអគ្គិសនី រយៈពេលនៃការដាច់ចរន្តអគ្គិសនី និងបង្កើនប្រសិទ្ធភាពថាមពលសម្រាប់អ្នកប្រើប្រាស់ ។ បន្ថែមពីនេះទៀតឧបករណ៍បញ្ជាផ្តាច់ភ្ជាប់ពីចម្ងាយ DRC-003 មិនត្រឹមតែមានសមត្ថភាពបង្កើនប្រសិទ្ធភាពថាមពល និងកាត់បន្ថយការបាត់បង់ថាមពលលើបណ្តាញនោះទេ ប៉ុន្តែថែមទាំងបង្កើនសុវត្ថិភាពដល់ក្រុមការងារបច្ចេកទេស នៅពេលធ្វើប្រតិបត្តិការណ៍ផងដែរ ។ ជាលទ្ធផលក្រុមការងារបច្ចេកទេស ក៏ដូចជាម្ចាស់អាជីវកម្មទទួលបានផលចំណេញជាច្រើនតាមរយៈការកាត់បន្ថយការចំណាយលើប្រតិបត្តិការណ៍ និងចំណាយលើទុនវិនិយោគដើម្បីធានាដល់ការផ្គត់ផ្គង់ថាមពលអគ្គីសនីទៅអតិថិជនគោលដៅរបស់ខ្លួនដោយទំនុកចិត្ត និងមានប្រសិទ្ធភាពខ្ពស់ ។

# II. គ្រឿងបរិក្ខារ



ឧបករណ៍បញ្ជាផ្តាច់ភ្ជាប់ពីចម្ងាយ DRC-003 ចំនួន ១



ជើងទម្រឧបករណ៍បញ្ជាផ្តាច់ភ្ជាប់ពីចម្ងាយ DRC-003 ចំនួន ១



អង់តែន GSM ចំនួន ១



ខ្សែបញ្ជូនទិន្នន័យ (Male to Female) ចំនួន ១



ខ្សែភ្លើងចរន្តជាប់ ចំនួន ១



ខ្សែចំណងជ័រ ចំនួន ៦



វីសមានក្បាលខ្មៅ ចំនួន ២

# III. ការដំឡើង

## សម្ភារសម្រាប់ដំឡើង



អូមម៉ែត្រ



ទួណឺវីសមុខ ៤



ដង្កាប់កាត់ខ្សែភ្លើង

# ដំណើរការដំឡើង DRC-003

**ចំណាំ**

- ចំពោះ Auto Recloser Cooper ដែលមាន firmware version ទាបជាង 2.34 ត្រូវធ្វើបច្ចុប្បន្នភាព firmware ទៅ 2.34 ។
- ចំពោះ Auto Recloser Cooper ដែលមាន firmware version ទាបជាង 3.03.08 ត្រូវធ្វើបច្ចុប្បន្នភាព firmware ទៅ 3.03.08 ។
- ចំពោះ Auto Recloser Cooper ដែលមាន firmware version ខ្ពស់ជាង 3.22.08 មិនតម្រូវឲ្យធ្វើបច្ចុប្បន្នភាពឡើយ ។

**01** បំពាក់ជើងទម្រឧបករណ៍បញ្ជាផ្តាច់ភ្ជាប់ពីចម្ងាយ DRC-003 នៅលើជើងទម្រក្នុងទូបញ្ជា Auto Recloser Cooper ។



**02** បំពាក់ឧបករណ៍បញ្ជាផ្តាច់ភ្ជាប់ពីចម្ងាយ DRC-003 នៅលើជើងទម្រ ។



**03** វាស់តង់ស្យុងចរន្តជាប់រវាងប៉ូល បូក (13.5V+) និង ដក (13.5V-) នៅលើឆ្នាប់ចរន្តដែលមាននៅក្នុងទូបញ្ជា មុនពេលភ្ជាប់ខ្សែភ្លើង ពីឧបករណ៍បញ្ជាផ្តាច់ភ្ជាប់ពីចម្ងាយ DRC-003 ទៅកាន់ឆ្នាប់ចរន្ត ។




**ចំណាំ**

- តង់ស្យុងសម្រាប់ដំណើរការ ចន្លោះពី ១២ ទៅ ២៤ វ៉ុល ។

**04** ភ្ជាប់ខ្សែភ្លើងចរន្តជាប់នឹងឆ្នាប់ចរន្ត ដោយខ្សែពណ៌ក្រហមសម្រាប់ប៉ូលបូក (+13.5V) និងខ្សែពណ៌ខ្មៅសម្រាប់ប៉ូលដក (-13.5V) ។



**05** ដោតខ្សែភ្លើងទៅក្នុងរន្ធ 24V ដែលស្ថិតនៅលើឧបករណ៍ បញ្ជាផ្ដាច់ភ្ជាប់ពីចម្ងាយ DRC-003 ចំហៀងខាងស្តាំ។




**06** ភ្ជាប់ខ្សែបញ្ជូនទិន្នន័យ (Female) ជាមួយនឹង RS232 Port នៅលើ Cooper Controller ។



**07** ភ្ជាប់ខ្សែបញ្ជូនទិន្នន័យ (Male) ជាមួយនឹង RS232 នៅលើ ឧបករណ៍បញ្ជាផ្ដាច់ភ្ជាប់ពីចម្ងាយ DRC-003 ។




**08** ដំឡើងខ្សែអង់តែន GSM នៅទីតាំងដែលអាចចាប់សេវា ទូរស័ព្ទបានល្អ ។



### ⚠ ចំណាំ

- ទីតាំង អង់តែន GSM ត្រូវតែដាក់នៅទីតាំងដែលអាចទទួល សេវាបានល្អ ។

**09** ភ្ជាប់ខ្សែអង់តែន GSM ទៅកាន់រន្ធ ANT នៅលើ ឧបករណ៍បញ្ជាផ្ដាច់ភ្ជាប់ពីចម្ងាយ DRC-003 ។




**10** ដាក់បញ្ចូលស៊ីមកាត ក្នុងរន្ធដាក់ស៊ីមកាត់នៅលើ ឧបករណ៍បញ្ជាផ្ដាច់ភ្ជាប់ពីចម្ងាយ DRC-003 ។



**11** ចុចប៊ូតុងដើម្បីបើកភ្លើងដំណើរការ ឧបករណ៍បញ្ជាផ្តាច់ភ្ជាប់ពីចម្ងាយ DRC-003 ។



**⚠ ចំណាំ**

- ឧបករណ៍បញ្ជាផ្តាច់ភ្ជាប់ពីចម្ងាយ DRC-003 ដំណើរការធម្មតា Running LED ភ្លឹបភ្លែតៗ រៀងរាល់ ១ វិនាទី ។
- សេវា GSM (GSM Connection) ដែលធ្វើការត្រឹមត្រូវ Net LED ភ្លឹបភ្លែតៗ រៀងរាល់ ៣ វិនាទី ។
- GSM Module ដំណើរការធម្មតា GSM LED ភ្លឺជាប់ ។

**12** ចុចប៊ូតុង "SUPERVISORY OFF" ។




**13** កំណត់ម៉ោងក្នុងតំបន់ ទៅ GMT +7:00 ។

> CLOCK

> UTC Time Zone

> GMT +7:00




**14** បិទ Negative Sequence ៖

> SETTINGS

> Modify

> OverCurrent

> Neg Seq Param

> Neg Seq Enable

> Disable



sale@vpstart.com | info@vpstart.com (+855) 23 888 167 | (+855) 86 666 677